ASIAN LAW CAUCUS

# របៀបបោះឆ្នោតនៅកាលីហ្វ័រញ៉ាខែវិច្ឆិកា ឆ្នាំ 2024

## ការត្រៀមខ្លួន

ប្រសិនបើអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ សូមចូលទៅកាន់គេហទំព័រ voterstatus.sos.ca.gov ដើម្បីប្រាកដថាព័ត៌មានរបស់អ្នកទាំងអស់មានភាពត្រឹមត្រូវ។

បើសិនជាអ្នកមិនទាន់បានចុះឈ្មោះបោះឆ្នោតឬលោកអ្នកចង់ចុះឈ្មោះបោះឆ្នោតក្នុងករណីដែលលោកអ្នកផ្លាស់ប្តូរទីកន្លែងឬប្តូរឈ្មោះរបស់លោកអ្នកនោះលោកអ្នកអាចចុះឈ្មោះតាមប្រព័ន្ធអនឡាញដោយប្រើគេហទំព័រ registertovote.ca.gov ឬបំពេញទម្រង់ឯកសារសម្រាប់ការចុះឈ្មោះបោះឆ្នោតនេះដែលមាននៅការិយាល័យគ្រប់គ្រងយានយន្ត(DMV) នៅមន្ទីរប្រៃសណីយ៍ផ្ញើសំបុត្រ នៅបណ្ណាល័យ ឬនៅមណ្ឌលបោះឆ្នោតប្រចាំស្រុករបស់លោកអ្នក។

អ្នកក៏អាចចុះឈ្មោះបានរហូតដល់ និងនៅថ្ងៃបោះឆ្នោត (ថ្ងៃអង្គារថ្ងៃទី 5 ខែវិច្ឆិកា)។ បន្ទាប់ពីថ្ងៃទី២១ខែតុលាទៅ អ្នកក៏អាចចុះឈ្មោះបោះឆ្នោតឬនៅក្នុងថ្ងៃបោះឆ្នោត(ថ្ងៃអង្គារទី៥វិច្ឆិកា)នៅការិយាល័យបោះឆ្នោតរបស់លោកអ្នកឬនៅការិយាល័យបោះឆ្នោតណាមួយ។

## ជម្រើសទី 1 - បោះឆ្នោតតាមសំបុត្រ



អ្នកអាចប្រគល់សន្លឹកឆ្នោតតាមរយៈសំបុត្រ។ ដោយមិនត្រូវការតែមប្រៃសណីយ៍ទេ! អ្នកគ្រាន់តែបំពេញសន្លឹកឆ្នោតរបស់អ្នក ដាក់វានៅក្នុងស្រោមសំបុត្រដែលបានផ្តល់អោយ ហើយចុះហត្ថលេខា កាលបរិច្ឆេទ និងបិទស្រោមសំបុត្រ។ ត្រូវឲ្យប្រាកដថាមានការបោះត្រារបស់ប្រៃសណីយ៍នៅថ្ងៃទី៥វិច្ឆិកា។



## ជម្រើសទី 2 - ទម្លាក់នៅការិយាល័យ

អ្នកអាចទម្លាក់សន្លឹកឆ្នោតរបស់អ្នកនៅការិយាល័យបោះឆ្នោតក្នុងខោនធីរបស់អ្នកឬទីតាំងបោះឆ្នោតណាមួយ។ តាមខោនធីភាគច្រើនក៏មានប្រអប់ទម្លាក់សុវត្ថិភាពដែលរកបានចាប់ពីដើមខែកុម្ភៈ។ អ្នកអាចរកមើលប្រអប់ទម្លាក់សន្លឹកឆ្នោតតាមរយៈ caearlyvoting.sos.ca.gov។

## ជម្រើសទី 3 - បោះឆ្នោតដោយផ្ទាល់



ថ្ងៃបោះឆ្នោតគឺនៅថ្ងៃអង្គារ ទី៥ ខែវិច្ឆិកា។ ការបោះឆ្នោតនឹងបើកពីម៉ោង **7** ព្រឹកដល់ម៉ោង **8** យប់។

អ្នកអាចរកមើលកន្លែងបោះឆ្នោតរបស់អ្នកតាមរយៈ sos.ca.gov/elections/polling-place។

ស្រុកជាច្រើនក៏នឹងអាចឲ្យលោកអ្នកបោះឆ្នោតបានចាប់ពីថ្ងៃសៅរ៍ទី**26**ខែតុលារហូតដល់ថ្ងៃអង្គារទី៥ខែវិច្ឆិកា សូមសាកសួរជាមួយនឹងការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នក ឬរកមើលទីតាំងបោះឆ្នោតតាមរយៈ caearlyvoting.sos.ca.gov។ ដើម្បីធ្វើឱ្យការបោះឆ្នោតដោយផ្ទាល់កាន់តែងាយស្រួល សូមយកសន្លឹកឆ្នោតដែលអ្នកបានទទួលតាមសំបុត្រទៅកាន់ទីតាំងបោះឆ្នោតរបស់អ្នក។